CITY OF LONG BEACH PUBLIC NOTICE

**ការជូនដំណឹងជាសាធារណៈ**

ថ្ងៃទី ៣០ ខែមិថុនាឆ្នាំ ២០២០

# ការបិទនៅទីក្រុងឡុងប៊ិចសម្រាប់ទិវាបុណ្យឯករាជ្យជាតិ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - បន្ថែមពីលើការបិទជាស្តង់ដារនៃទីតាំងនិងសេវាកម្មរបស់ទីក្រុងឡុងប៊ិចក្នុងថ្ងៃឈប់សម្រាកមួយចំនួនសេវាកម្មនិងធនធានទីក្រុងបន្ថែមដែលបានអនុម័តសម្រាប់ការឆ្លើយតបនឹងជម្ងឺ COVID-19 ក៏នឹងត្រូវបិទផងដែរនៅក្នុងការប្រារព្ធទិវាបុណ្យឯករាជ្យជាតិ។

អគារនិងសេវាកម្មរបស់ទីក្រុងដែលមានខាងក្រោមនឹងគោរពតាមកាលវិភាគដូចខាងក្រោមនៅថ្ងៃសុក្រទី ៣ ខែកក្កដាឆ្នាំ ២០២០។ សាលាក្រុងនៅតែបិទទ្វារជាសាធារណៈរហូតដល់មានការជូនដំណឹងបន្ថែម។

**បិទនៅថ្ងៃសុក្រទី ៣ ខែកក្កដា៖**

- សេវាកម្មថែទាំសត្វនិង spcaLA*
- មជ្ឈមណ្ឌលផ្លាស់ប្តូរអាជីព*
- មជ្ឈមណ្ឌលសម្រាប់គ្រួសារដែលធ្វើការ*
- សាលាក្រុង*
- គណៈកម្មការពលរដ្ឋសម្រាប់ទទួលការបណ្តឹងប៉ូលីស
- សេវាកម្មអនុវត្តក្រម (ក្រុមការងារពិសេសនឹងបន្តប្រតិបត្តិការពេញមួយចុងសប្តាហ៍)
- ទីស្នាក់ការកណ្តាលនៃក្រសួងពន្លត់អគ្គីភ័យ សេវាកម្មគាំទ្រ ក្រុមបង្ការអគ្គិភ័យនិងក្រុមប្រតិបត្តិការរួមទាំងរដ្ឋបាលសុវត្ថិភាពខាងសមុទ្រ
- ក្រសួងសុខាភិបាលនិងមូលដ្ឋានសុខាភិបាល
- អាជ្ញាធរលំនៅដ្ឋាន

- មជ្ឈមណ្ឌលធនធានអ្នកជិតខាង*
- ការិយាល័យការងារ (The WorkPlace) មជ្ឈមណ្ឌលឱកាសយុវជននិងការិយាល័យរដ្ឋបាល Pacific Gateway*
- ការិយាល័យឧទ្យាននិងកន្លែងសួនសហគមន៍*
- ការបោសថ្នល់
- ការទាញនិងលក់រថយន្តនិងយានថយន្តផ្សេងៗដែលម្ចាស់មិនមកបង់រំលួស់
- ក្រសួងទឹក (ភាពអាសន្ននៃទឹកឬលូ៖ 562.570.2390)

**បើកនៅថ្ងៃសុក្រទី ៣ ខែកក្កដាដោយមានការកែប្រែលើប្រតិបត្តិការមួយចំនួន៖**

- ស្ថានីយ៍អគ្គីភ័យនិងស្ថានីយការពារជីវិតពីការលង់ទឹក
- ឧទ្យាន El Dorado Regional* (សម្រាប់ការកំសាន្តសកម្មតែប៉ុណ្ណោះ។ មិនអនុញ្ញាតឱ្យមានការប្រមូលផ្តុំឬការលេងកីឡាជាក្រុមឡើយ)
- ការិយាល័យខាងមុខទីស្នាក់ការប៉ូលីស
- ការិយាល័យកំពង់ផែ (កំពង់ផែ Alamitos Bay, កំពង់ផែ Shoreline)*
- ការប្រមូលសំរាមនិងរបស់ដែលអាចកែច្នៃឡើងវិញបាន (ការិយាល័យនឹងត្រូវបិទប៉ុន្តែសំរាមនិងរបស់របរដែលអាចកែច្នៃឡើងវិញបាននឹងត្រូវប្រមូលដូចធម្មតា)
- ក្រុមបញ្ជូនសេវាកម្មហ្គាសបើក ២៤ ម៉ោង ៧ ថ្ងៃក្នុងមួយសប្តាហ៍សំរាប់ការទទួលទូរស័ព្ទបន្ទាន់នៅលេខ 562.570.2140

*សញ្ញានេះ (*) ចង្អុលបង្ហាញអំពីទីតាំងនិងសេវាកម្មទីក្រុងដែលកំពុង[ប្រតិបត្តិការដោយមានការកែប្រែ]មួយចំនួនរហូតដល់មានការជូនដំណឹងបន្ថែម។ ការកែប្រែទាំងនេះគឺជាលទ្ធផលនៃការរឹតត្បិតផ្នែកចម្ងាយរាងកាយខណៈពេលនៅមានជម្ងឺ COVID-19។*

**បើកនៅថ្ងៃសុក្រទី ៣ ខែកក្កដានិងបិទនៅថ្ងៃសៅរ៍ទី ៤ ខែកក្កដា៖**

- មជ្ឈមណ្ឌលធម្មជាតិ El Dorado*
- អាងហែលទឹក*

**សាលាក្រុង**

សាលាក្រុងបានបិទការចូលជាសាធារណៈនៅថ្ងៃទី ១៨ ខែមីនាហើយនឹងនៅតែបិទរហូតដល់មានការជូនដំណឹងបន្ថែម។ ប្រជាជនត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់សេវាកម្មតាមអ៊ិនធឺរណែតក្នុងអំឡុងពេលនេះ។

## ការបោសផ្លូវ

មិនមានការបោសផ្លូវឬការអនុវត្តន៍ចំពោះការបំពានច្បាប់បោសផ្លូវនៅថ្ងៃសុក្រទី ៣ ខែកក្កដាឡើយ។

## ការអនុវត្តច្បាប់ចំណតរថយន្ត

សូមមេត្តាអានម៉ែត្រចំណតរបស់លោកអ្នក៖ ម៉ែត្រចំណតនឹងនូវតែអនុវត្តនៅថ្ងៃសៅរ៍ទី ៤ ខែកក្កដាលើកលែងតែម៉ែត្រនោះសរសេរថា "លើកលែងនៅថ្ងៃបុណ្យទាន (Exempt on Holidays)។" ថ្ងៃនិងម៉ោងនៃការអនុវត្តច្បាប់មានសរសេរនៅខាងក្នុងម៉ែត្រ។

## សំរាមនិងរបស់ដែលអាចកែច្នៃឡើងវិញបាន

សំរាមនិងរបស់ដែលអាចកែច្នៃឡើងវិញបាននឹងត្រូវប្រមូលតាមការគ្រោងទុកដូចធម្មតានៅថ្ងៃសុក្រទី ៣ ខែកក្កដា។

## ការទាញនិងលក់រថយន្តនិងយានថយន្តផ្សេងៗដែលម្ចាស់មិនមកបង់រំលួស់

កន្លែងប្រតិបត្តិការទាញនិងកន្លែងផ្ទុកយានយន្តដែលមានទីតាំងនៅ 3111 E. Willow St. ដែលស្ថិតនៅចន្លោះផ្លូវ Temple Avenue និងផ្លូវ Redondo Avenue នឹងត្រូវបិទនៅថ្ងៃសុក្រទី ៣ ខែកក្កដានិងថ្ងៃសៅរ៍ទី ៤ ខែកក្កដា។ ម៉ោងធ្វើការធម្មតាគឺ៖

- ថ្ងៃច័ន្ទដល់ថ្ងៃសុក្រម៉ោង ៨ ព្រឹកដល់ម៉ោង ៥ ល្ងាច។
- ថ្ងៃសៅរ៍ពីម៉ោង ៨ ព្រឹកដល់ម៉ោង ៤ ល្ងាច។
- បិទនៅថ្ងៃអាទិត្យនិងនៅថ្ងៃបុណ្យទាន។

យានយន្តនិងទ្រព្យសម្បត្តិគឺអាចមកបង់រំលួស់បាននៅក្រៅម៉ោងដែលបានរៀបរាប់ខាងលើជាមួយនឹងថ្លៃសេវាបន្ថែម។ ព័ត៌មានបន្ថែមអាចរកបានតាមអ៊ីនធឺណិត។

## បណ្ណាល័យ

បណ្ណាល័យសាធារណៈទាំងអស់នៅឡុងប៊ិចបានបិទជាសាធារណៈនៅថ្ងៃទី ១៨ ខែមីនាហើយនឹងនៅតែបិទរហូតដល់មានការជូនដំណឹងបន្ថែម។ ការមកយករបស់ខ្ចីដោយមិនចាំបាច់មានការទំនាក់ទំនងដែលជាសេវាកម្មផ្តល់ជូននៅទីតាំងមួយចំនួននឹងមិនមាននៅថ្ងៃសុក្រទី ៣ ខែកក្កដាឬថ្ងៃសៅរ៍ទី ៤ ខែកក្កដាទេ។ អ្នកដែលចូលប្រើបណ្ណាល័យត្រូវបានលើកទឹកចិត្តអោយប្រើប្រាស់ធនធានឌីជីថលយ៉ាងច្រើនរបស់បណ្ណាល័យឡុងប៊ិចរួមមានកាតាឡុកបណ្ណាល័យ ធនធានដែលអាចទាញយកពីអ៊ីនធឺណិតនិងមូលដ្ឋានទិន្នន័យដែលអាចរកបាន ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៍។ ខ្សែទូរស័ព្ទរបស់បណ្ណាល័យ (562.570.7500) ដែលជាធម្មតាអាចប្រើបានចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃអង្គាររហូតដល់ថ្ងៃសៅរ៍នឹងត្រូវបិទនៅថ្ងៃសុក្រទី ៣ ខែកក្កដានិងថ្ងៃសៅរ៍ទី ៤ ខែកក្កដាដើម្បីប្រារព្ធទិវាបុណ្យឯករាជ្យជាតិ។

**ការបិទនូវសេវាកម្មនិងធនធានឆ្លើយតបនឹងជម្ងឺ COVID-19 នៃទីក្រុងក្នុងថ្ងៃបុណ្យទាននៅចុងសប្តាហ៍៖**

- ឆ្នេរទាំងអស់រួមទាំងផ្លូវជិះកង់និងផ្លូវថ្មើរជើងនឹងត្រូវបិទចាប់ពីថ្ងៃទី ៣ ដល់ថ្ងៃទី ៦ ខែកក្កដា។ សូមអានព័ត៌មានលម្អិតនៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ទីក្រុង។
- ទីតាំងធ្វើតេស្តទាំងអស់នៅឡុងប៊ិចសម្រាប់ជម្ងឺ COVID-19 នឹងត្រូវបិទចាប់ពីថ្ងៃសុក្រទី ៣ ខែកក្កដារហូតដល់ថ្ងៃអាទិត្យទី ៥ ខែកក្កដាលើកលែងតែសាលារៀន Jordan (6500 Atlantic Ave.) ដែលនឹងត្រូវបើកនៅថ្ងៃសុក្រទី ៣ ខែកក្កដាចាប់ពីម៉ោង ៣ រសៀលដល់ម៉ោង ៥ ល្ងាចនិងសាលារៀន Cabrillo ដែលនឹងត្រូវបើកពីម៉ោង ១១ ព្រឹកដល់ម៉ោង ១ រសៀលនៅថ្ងៃសុក្រទី ៣ ខែកក្កដា។ ទីក្រុងបានបន្ថែមកន្លែងធ្វើតេស្តបន្ថែមក្នុងរយៈពេលប៉ុន្មានថ្ងៃដែលឈានដល់ថ្ងៃឈប់សម្រាកចុងសប្តាហ៍នេះក៏ដូចជានៅសប្តាហ៍ក្រោយផងដែរដើម្បីបំពេញតំរូវការអ្នកចង់ធ្វើតេស្ត។
- គ្លីនិកធ្វើរោគវិនិច្ឆ័យរហ័ស (RAC) នឹងត្រូវបិទនៅថ្ងៃសុក្រទី ៣ ខែកក្កដាដល់ថ្ងៃអាទិត្យទី ៥ ខែកក្កដា។
- មជ្ឈមណ្ឌលព័ត៌មានរួម (សម្រាប់អ្នកសារព័ត៌មាន) និងបណ្តាញព័ត៌មានបន្ទាន់ (សម្រាប់សហគមន៍) នឹងបិទប្រតិបត្តិការនៅថ្ងៃសុក្រទី ៣ ខែកក្កដា។

ការសាកសួរពីសារព័ត៌មានអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលព័ត៌មានរួមតាមលេខ 562.570.6397 ឬផ្ញើអ៊ីមែលទៅ jic@longbeach.gov។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #